**San Diego Unified School District**
**Office of the Associate Superintendent**
**Special Projects Division**
**Program Monitoring Department**

# ច្បាប់ទាក់ទងមាតាបិតាសាលារៀនដែលមានកម្មវិធី Title I
# ព្រមទាំងលំនាំសំរាប់ការប្រតិបត្តិ

ដើម្បីរួមសហការណ៏ជាដៃគូជាមួយសាលារៀនដែលមានកម្មវិធី Title I , មាតាបិតា ព្រមទាំងសហគមន៏, គណៈកម្មការក្រសួងអប់រំ យើងត្រូវតែអនុវត្តន៏កិច្ចការតាមការគ្រប់គ្រងដើម្បីធ្វើការផ្តាច់ញ៉ា:

## ១. សហការណ៏ជាមួយមាតាបិតា/អ្នកអាណាព្យាបាលសិស្ស ដើម្បីចូលរួមបង្កើតគម្រោងការ Title I របស់ក្រសួងអប់រំប្រចាំក្រុង ព្រមទាំងសើរើសាលារៀនអោយមានដំណើរការល្អ និងមានការរីកចំរើន។

ក្រសួងអប់រំប្រចាំក្រុងនឹងផ្តល់ឱកាសដល់មាតាបិតាចូលរួមសហការណ៏តាម:

a. ការចូលរួមក្នុងការបង្កើត ឬសើរើគម្រោងការអប់រំប្រចាំស្រុក (LEA)។
b. ការចូលរួមការអោយតម្លៃទៅលើគម្រោងការ LEA ជាប្រចាំឆ្នាំធ្វើឡើងដោយគណៈកម្មការទីប្រឹក្សាក្រសួងអប់រំប្រចាំក្រុង (DAC) សំរាប់កម្មវិធីអប់រំ។
c. ការចែកចាយពត៏មានតាមគណៈកម្មការក្រសួងអប់រំប្រចាំក្រុងធ្វើសេចក្តីរាយការណ៏ (BOE) ប្រចាំតំបន់តាមប្រព័ន web page របស់ក្រសួងអប់រំប្រចាំក្រុង, និងតាមសេចក្តីរាយការណ៏ BOE ប្រចាំតំបន់ ប្រជុំ DAC អំពី ការរីកចំរើរបស់សាលារៀននិមួយៗ ពេលប្រជុំការគ្រប់គ្រងទាំងអស់។ (ការរីកចំរើនគ្រប់គ្រាន់ចាប្រចាំឆ្នាំ, ការសិក្សាបន្ថែម, កិច្ចព្រមព្រៀងគ្រប់គ្រងសាលារៀនប្រចាំក្រុង)។

## ២. ផ្តល់ការសម្របសម្រួល, ជំនួយខាងផ្នែក បច្ចេកទេស និងការគាំទ្រជាចាំបាច់ផ្សេងៗ ដើម្បីជួយសាលារៀនចូលរួមក្នុងការរៀបចំគម្រោងការអប់រំនិងប្រតិបត្តិការរួមសហការណ៏មាតាបិតាអោយមានប្រសិទ្ធិភាពដើម្បីពង្រឹងការសិក្សាសិស្សអោយបានសម្រេច ព្រមទាំងសាលារៀនផ្តល់ការអប់រំសិស្សបានល្អប្រពៃ។

ក្រសួងអប់រំប្រចាំក្រុងនឹង:

a. ផ្តល់មណ្ឌលហ្វឹកហ្វឺនតាមមជ្ឈមណ្ឌលមាតាបិតា Harold J. Ballard.
b. ផ្តល់មជ្ឈមណ្ឌលហ្វឹកហ្វឺនសំរាប់ គណៈកម្មការទីប្រឹក្សាប្រចាំសាលារៀន និងគណៈកម្មការទីប្រឹក្សាណែនាំសិស្សរៀន អង់គ្លេស តាមរយៈក្រសួងផ្នែកកម្មវិធីត្រួតពិនិត្យ។
c. ផ្តល់កម្មវិធីហ្វឹកហ្វឺនដល់មាតាបិតាដែលស្នាក់បំរើដល់សាលារៀនតាមការិយាល័យដែលជាដៃគូរ។
d. ផ្តល់ការហ្វឹកហ្វឺនដល់បុគ្គលិក និង/ឬសម្ភារះសំរាប់មាតាបិតាចូលរួមសហការណ៏អោយមានប្រសិទ្ធភាពដើម្បីពង្រឹងការសិក្សាសិស្សអោយបានសម្រេច។

## ៣. រៀបចំចាត់ចែងស្ថាបនាសាលារៀន, បុគ្គលិក, ព្រមទាំងមាតាបិតា/អ្នកអាណាព្យាបាលអោយបានរឹងមាំ, មានប្រសិទ្ធិភាព, ព្រមទាំងមាតាបិតាអាចចូលរួមជាចំណែកជាមួយកូនសិក្សាដើម្បីពង្រឹងការសិក្សាសិស្សអោយបានសម្រេច។

ក្រសួងអប់រំប្រចាំក្រុងនឹង:

a. ផ្តល់ការហ្វឹកហ្វឺនផ្នែក ដឹកនាំ សំរាប់មាតាបិតានៅតាមមជ្ឈមណ្ឌលមាតាបិតា Harold J. Ballard.
b. ផ្តល់ការហ្វឹកហ្វឺនដល់សមាជិកគណៈកម្មការទីប្រឹក្សាប្រចាំសាលារៀនតាមរយៈក្រសួងផ្នែកកម្មវិធីត្រួតពិនិត្យ។
c. ផ្តល់ថ្នាក់បង្រៀន University សំរាប់មាតាបិតាទាំងអស់នៅតាមមជ្ឈមណ្ឌលមាតាបិតា Harold J. Ballard.
d. ផ្តល់ការហ្វឹកហ្វឺនសំរាប់សមាជិកគណៈកម្មការទីប្រឹក្សាក្រសួងអប់រំប្រចាំក្រុង (DAC) នូវកិច្ចការ Title I ទាំងអស់ នៅពេលមានការប្រជុំជាប្រចាំខែ។

**៤. សម្របសម្រួល និងការបញ្ចូលនូវយុទ្ធវិធីសហការណ៏មាតាបិតា Title I ជាមួយយុទ្ធវិធីសហការណ៏មាតាបិតាដែលនៅក្រោមកម្មវិធីផ្សេងៗ**

ក្រសួងអប់រំប្រចាំក្រុងនឹងផ្តល់ការសម្របសម្រួលរវាង:

a. មជ្ឈមណ្ឌលផ្តល់ពត៌មានមាតាបិតា California (CPRC) នឹងមជ្ឈមណ្ឌលមាតាបិតា Harold J. Ballard.
b. មាតាបិតាក្រសួងអប់រំប្រចាំទីក្រុង San Diego, សហគមន៍, និងផ្នែកទាក់ទងសិស្ស ព្រមទាំងមជ្ឈមណ្ឌលមាតាបិតា Harold J. Ballard.
c. ក្រសួងអប់រំប្រចាំទីក្រុង San Diego កម្មវិធីបណ្តុះបណ្តាលសិស្ស ព្រមទាំងមជ្ឈមណ្ឌលមាតាបិតា Harold J. Ballard.

**៥. ជាមួយនឹងការរួមសហការណ៏មាតាបិតា/អ្នកអាណាព្យាបាល ធ្វើការអោយតម្លៃចាប្រចាំឆ្នាំនូវមាតិការ និងច្បាប់ការរួមសហការណ៏មាតាបិតាអោយមានប្រសិទ្ធិភាពដើម្បីផ្តល់គុណភាពបង្រៀនដែលសាលារៀនបានបំរើដែលធ្វើឡើងដោយកម្មវិធី Title I រួមនឹង:**

- បញ្ជាក់អំពី បញ្ហានៃការចូលរួមរបស់មាតាបិតា/អ្នកអាណាព្យាបាលសិស្សជាមួយការសិក្សារបស់សិស្ស ជាពិសេសសំរាប់មាតាបិតា/អ្នកអាណាព្យាបាលដែលកូនមានបញ្ហាសិក្សា, ចេះភាសា English មិនគ្រប់គ្រាន់ ហើយជាសិស្សជនជាតិភាគតិច។
- ផ្តល់នូវរបៀបដើម្បីស្វែងរកយុទ្ធវិធីសំរាប់ការណែនាំមាតាបិតាអោយចូលរួមសហការណ៏អោយមានប្រសិទ្ធិភាព។
- បើមានការចាំបាច់ សើរើនូវច្បាប់ក្រសួងអប់រំប្រចាំក្រុង និងច្បាប់សំរាប់មាតាបិតាចូលរួមសហការណ៏។

ក្រសួងអប់រំប្រចាំក្រុងនឹង:

a. ផ្តល់ការសម្រួលកិច្ចការបកប្រែ ពេលមានប្រជុំមាតាបិតា/សហគមន៍។
b. ចូលរួមការអោយតម្លៃជាប្រចាំឆ្នាំទៅលើច្បាប់សហការណ៏មាតាបិតារបស់ក្រសួងអប់រំប្រចាំក្រុង, ធ្វើការប្រមូល និងធ្វើសេចក្តីរាយការណ៏ទៅលើក្រុមអោយតម្លៃទាំងអស់របស់ក្រសួងអប់រំប្រចាំក្រុងដែលធ្វើឡើងដោយគណៈកម្មការទីប្រឹក្សាក្រសួងអប់រំប្រចាំក្រុង (DAC) ដើម្បីទូទាត់ថវិការសំរាប់កម្មវិធីអប់រំ។
c. ចូលរួមសើរើច្បាប់សហការណ៏មាតាបិតារបស់ក្រសួងអប់រំប្រចាំក្រុង យោងទៅតាមលទ្ធផលនៃការអោយតម្លៃ បើមានការចាំបាច់។
d. បើកកម្មវិធីសើរើគណៈកម្មការទីប្រឹក្សាក្រសួងអប់រំប្រចាំក្រុង (DAC) ដើម្បីសម្របសម្រួលតាមយោបល់-មតិក្នុងការស្នើថវិការ។

**៦. ណែនាំមាតាបិតា/អ្នកអាណាព្យាបាលសិស្សអោយចូលរួមជាមួយកម្មវិធីសិស្សនៅតាមសាលារៀន/យុទ្ធវិធីនៅតាមសាលារៀនដែលធ្វើឡើងដោយកម្មវិធី Title I.**

ក្រសួងអប់រំប្រចាំក្រុងនឹងអនុវត្តន៍អោយបានប្រាកដថា:

a. ការប្រស្រ័យទាក់ទងជារបៀបពីរ-ផ្លូវ គឺមានន័យគ្រប់គ្រាន់នៅតាមកំរិតសាលារៀន និងក្រសួងអប់រំប្រចាំក្រុង ដូចគម្រោងនៅក្នុងច្បាប់របស់ក្រសួងអប់រំប្រចាំក្រុង។
b. នៅតាមសាលារៀនដែលមានកម្មវិធី Title I ទទួលថវិការដើម្បីពង្រឹងមេរៀនពង្រឹងការរួមសហការណ៏មាតាបិតា។
c. ការប្រជុំត្រូវធ្វើឡើងនៅពេលវេលាដ៏សមរម្យចំពោះការចូលរួមនៃមាតាបិតាសិស្ស។
b. មាតាបិតានឹងបានទទួលពត៌មាន ពេលសាលារៀនត្រូវបានធ្លាក់នៅក្នុងចំណាត់កម្មវិធីពង្រឹងការគ្រប់គ្រងសិក្សា ហើយសិស្សអាចចូលរួមជាមួយកម្មវិធីសិក្សាជ្រើសរើស/បំរើបាន ក្រោមកម្មវិធីពង្រឹងការគ្រប់គ្រងការសិក្សាជ្រើសរើស និង/ឬការបងំរើផ្នែកអប់រំបន្ថែម។